# របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម

**កម្មវិធីរបស់ the Asian International Justice Initiative**

ឆ្នាំទី១ លេខ ៤ សប្តាហ៍ទី ៤ (២៧ ‒ ៣០ មេសា ឆ្នាំ២០០៩)


## "សវនាការអង្គសេចក្តីលើករណីអតីតប្រធានមន្ទីរ ស-២១ កាំង ហ្គិចអាវ ហៅ ឌុច"



***រូបភាព :*** *ឌុចឆ្លើយនៅក្នុងសវនាការថា ការងារមួយផ្នែកធំរបស់គាត់ គឺបង្រៀនកម្មាភិបាលឱ្យចេះធ្វើទារុណកម្ម និងកំទេចអ្នកទោស*

### ១. សេចក្តីសង្ខេប

***"យោងតាមច្បាប់កម្ពុជា គណៈអចិន្ត្រៃយ៍តំបន់... គណៈការិយាល័យមជ្ឈិមបក្ស គណៈអចិន្ត្រៃយ៍ និងនាយសេនាធិការ... គឺជាក្រុមមនុស្ស ដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មនានា" ។***

ដំណើរការជំនុំជម្រះនាសប្តាហ៍នេះ ផ្តោតទៅលើការចោទសួរជនជាប់ចោទ ដែលជាបឋមស្តីពីការបង្កើតមន្ទីរ ស-២១ បន្តពីសប្តាហ៍មុន និងអង្គហេតុថ្មី ស្តីពីការអនុវត្តន៍គោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យនៅមន្ទីរ ស-២១ ។ ការសួរតទល់ជនជាប់ចោទចំពោះចំណុចខាងលើនឹងបន្តទៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ បន្ទាប់ពីការផ្អាកដំណើរការនីតិវិធី រយៈពេលពីរសប្តាហ៍។ អង្គជំនុំជម្រះបានបង្ហាញការប្តេជ្ញាចិត្តយ៉ាងមុតមាំ ដើម្បីពន្លឿននីតិវិធី ដោយក្រើនរំលឹកភាគីជាញឹកញាប់កុំឱ្យចោទសួរចាកឆ្ងាយពីប្រធានបទដែលបានកំណត់ និងចៀសវាងការចោទសួរសំណួរដដែលៗ ព្រមទាំងប្រកាសថា នឹងបង្អាក់សំណួរ ដែលអង្គជំនុំជម្រះយល់ថាមិនពាក់ព័ន្ធ ។ ទោះបីជាយ៉ាងណាក៏ដោយ ដំណើរការនីតិវិធីមិនបានប្រព្រឹត្តទៅតាមការគ្រោងទុកទេ គឺនៅតែ

យឺតជាងកាលកំណត់ ដោយអង្គហេតុពាក់ព័ន្ធនឹងការអនុវត្តន៍គោលនយោបាយកម្ពុជាប្រជាធិបតេយ្យនៅមន្ទីរ ស-២១ ទើបចាប់ផ្តើមនៅថ្ងៃពុធនេះ ។ អង្គជំនុំជម្រះបានជូនដំណឹងនៅរសៀលថ្ងៃព្រហស្បតិ៍ថា ខ្លួនបានចេញ និងចែកជូនកាលវិភាគសវនាការថ្មីដែលមានដល់ខែមិថុនា ដល់គ្រប់ភាគីរួចហើយ ។

## ២. បញ្ហាច្បាប់ និងនីតិវិធី

### ក. សក្ខីភាពសខេមបរស់ជនជាប់ចោទ

នៅថ្ងៃច័ន្ទ និងថ្ងៃអង្គារ សហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងបានចោទសួរជនជាប់ចោទជាច្រើនអំពីអង្គហេតុការបង្កើតមន្ទីរ ស-២១ កំឡុងពេល **ឌុច** ជាប្រធាននៅទីនោះ ។ ជនជាប់ចោទបានបញ្ជាក់ពីជំហរដែលថា គាត់គ្រាន់តែធ្វើតាមបញ្ជាថ្នាក់លើតែប៉ុណ្ណោះ បើទោះបីជាគាត់មានសិទ្ធិសម្រេចការងារមួយចំនួនក្នុងនាមគាត់ជាប្រធានក៏ដោយ ។ គាត់ថែមទាំងអះអាងថា គាត់ធ្លាប់សួរចម្លើយអ្នកទោសបានតែម្នាក់គត់ ។

***គុកតាខ្មៅ :*** គុកតាខ្មៅដែលជាអតីតមន្ទីរពេទ្យឆ្កួតបានក្លាយជាមន្ទីរឃុំឃាំងបន្ទាប់ពីប៉ុន្មានថ្ងៃក្រោយ ថ្ងៃ១៧ មេសា ១៩៧៥ ។ ភស្តុតាងនៅគុកនេះទំនងជាមានសារៈសំខាន់សម្រាប់អង្គជំនុំជម្រះធ្វើការស្វែងយល់អំពីការបង្កើតមន្ទីរ ស-២១ ដោយសារអង្គហេតុដែលថា អ្នកទោសមួយចំនួនយកមកសួរចម្លើយនៅមន្ទីរ ស-២១ និងជាអ្នកដែលជាប់ឃុំនៅទីនោះ ។ ជនជាប់ចោទបានឱ្យដឹងថា នៅពេលនោះ **ណាត** ជាប្រធាន រហូតដល់ ខែសីហា ១៩៧៦ ។

***ការរៀបចំរចនាសម្ព័ន្ធនៃមន្ទីរ ស-២១ និងគុកព្រៃសរ :*** កាលពីសប្តាហ៍មុន មានការសួរដេញដោលជាច្រើនអំពីអង្គភាពសួរចម្លើយ ហើយ **ឌុច** បានពន្យល់ពីដំណើរការ និងតួនាទីរបស់គាត់នៅមន្ទីរ ស-២១ ទាំងមូល ព្រមទាំងព័ត៌មានលម្អិតអំពីអង្គភាពនីមួយៗ ដែលស្ថិតក្រោមបង្គាប់របស់គាត់ រួមមាន អង្គភាពយោធា អង្គភាពវាយអង្គុលីលេខ អង្គភាពទំនាក់ទំនងនិងភ្ជាប់ខ្សែទូរស័ព្ទ អង្គភាពថតរូប អង្គភាពម្ហូបអាហារនិងផលិតផល អង្គភាពពេទ្យ និងអង្គភាពគូរផែនទី ។ អង្គភាពសំខាន់ជាងគេ គឺអង្គភាពយោធា (អង្គភាពពិសេស) តួនាទីរបស់វា គឺប្រើប្រាស់ដើម្បីទទួលជនរងគ្រោះ និងចុះឈ្មោះអ្នកទោស ។ តំបន់ជើងឯកប្រើសម្រាប់កប់សាកសព ។ ឯគុកព្រៃសរប្រើជាកន្លែងកែប្រែ ចំពោះអ្នកទោសល្មើសវិន័យ និងប្រើសម្រាប់ដាំដុះផងដែរ ។

### ការអនុវត្តន៍គោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យនៅមន្ទីរ ស-២១

***គោលនយោបាយ :*** ចុងសប្តាហ៍នេះ អង្គជំនុំជម្រះបានសួរដេញដោលពីគោលគំនិតមនោគមវិជ្ជារបស់ខ្មែរក្រហម និងគោលគំនិតនៃការបង្កើតមន្ទីរ ស-២១ ។ **ឌុច** បានអះអាងថា គាត់មានជំនឿលើ *"ទស្សនៈសង្គមនិយម និងសង្គមម៉ាកលេនីននិយម"* កាលគាត់នៅក្មេង ប៉ុន្តែគាត់ស្រងាកចិត្តជាខ្លាំង បន្ទាប់ពីការបែកភ្នំពេញកាលពីថ្ងៃ១៧ មេសា ១៩៧៥ ដោយសារមានការបង្ហូរឈាមខ្មែរ ។ ទាំងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ និងលក្ខន្តិកៈបក្សត្រូវបានពិភាក្សាលំអិត ។ លោកចៅក្រម **Lavergne** បានសួរបញ្ជាក់អំពីអត្ថន័យនៃផ្នែកនីមួយៗនៃឯកសារនោះ ។ **ឌុច** កត់សម្គាល់ថា សមាជិកបក្សត្រូវបានលើកទឹកចិត្តឱ្យរក្សាគោលជំហររឹងមាំឆ្ពោះទៅ មុខតាមដាន និងកំទេចសត្រូវ ដើម្បីរក្សាគោលជំហរបក្ស *"ស្អាត និងបរិសុទ្ធ"* ។ ចំពោះអត្ថន័យនៃពាក្យ *"សត្រូវ"*

ហាក់ដូចជាត្រូវបានផ្លាស់ប្តូរគ្រប់ពេលវេលា ។ នៅពេលសួរ ថាតើការខិតចូលនៃលទ្ធិកុម្មុយនីសរបស់ **ប៉ុល ពត** គឺដោយសារម៉ៅ? **ឌុច** បានឱ្យដឹងថា វាមិនមែនតែ ម៉ៅ ទេ ប៉ុន្តែ **ប៉ុល ពត** បានអនុវត្តហួស និងកាចសាហាវជាងលទ្ធិម៉ៅទៅទៀត ។

***ការកំទេច និងការបោសសំអាត :*** **ឌុច** បានផ្តល់សក្ខីភាពថា បញ្ហានេះដោយសារតែមនុស្សដែលមានអំណាចក្នុងការបញ្ជាឱ្យកំទេច និងបោសសំអាត ។ ក្រុមមនុស្សទាំងបួនក្រុមនោះ រួមមាន *គណៈអចិន្ត្រៃយ៍តំបន់* (សម្រាប់ថ្នាក់មូលដ្ឋាន) *គណៈការិយាល័យមជ្ឈឹមបក្ស* (សម្រាប់តំបន់ជុំវិញការិយាល័យកណ្តាល) *គណៈអចិន្ត្រៃយ៍* (សម្រាប់តំបន់ឯករាជ្យ) *និងនាយសេនាធិការ* (សម្រាប់តំបន់យោធា) ។ **ឌុច** ក៏បានអះអាងថា ការបោសសំអាតមានពីតំណាក់កាល គឺកំឡុងថ្ងៃ១៧ មេសា ១៩៧៥ (នៅពេលដែលបក្សផ្តោតសំខាន់ទៅលើការបោសសំអាតមន្ត្រីរាជការ ប៉ូលីស និងទាហ៊ាន នៅសម័យ លន់ ណុល) និងបន្ទាប់មកគណៈអចិន្ត្រៃយ៍សម្រេចកាលពីថ្ងៃទី៣០ មិនា ១៩៧៦ (ដែលរួមបញ្ចូលការបោសសំអាតផ្ទៃក្នុង) ។

### ខ. បញ្ហាដែលអង្កេតឃើញនៅពេលសវនាការ

***"ការដាក់ជូនឯកសារ" ឯកសារដែលភាគីជ្រើសរើសពីសំណុំរឿង :*** កាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន បន្ទាប់ពីសុំអនុញ្ញាតពីអង្គជំនុំជម្រះ ដើម្បីចែកជូនភាគីនូវឯកសារជ្រើសរើសចេញពីសំណុំរឿង មេធាវីការពារក្តីបានបដិសេធលើកឡើងដោយផ្ទាល់កាលពីព្រឹកថ្ងៃច័ន្ទ ចំពោះការចែកជូនឯកសារចងក្រងនេះ ។ លោក **Alex Bates** សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា ដោយសារការចងក្រងឯកសារចេញមកពីសំណុំរឿង ដូច្នេះគ្មានការវិភាគ ឬអធិប្បាយពីសហព្រះរាជអាជ្ញាឡើយ ហើយយោងតាមវិធាន៩២ ការចងក្រងឯកសារនេះមិនគប្បីចាត់ទុកថាជា *"ការដាក់ជូនឯកសារ"* ទេ ។ លើសពីនេះទៀត លោកសហព្រះរាជអាជ្ញាទទូចថា សហព្រះរាជអាជ្ញាមានសិទ្ធិជ្រើសរើសឯកសារ ដើម្បីធ្វើជាភស្តុតាងលើអង្គហេតុណាមួយ ហើយភាគីដទៃក៏មានសិទ្ធិដូចគ្នាដែរ ។ មេធាវីការពារក្តីបានលើកវិញថា ទម្រង់នៃការចងក្រងឯកសារនេះមានន័យថាជា *"ការដាក់ជូនឯកសារ"* (ឬជ្រើសរើសដើម្បីគាំទ្រ) សំណុំឯកសាររបស់សហព្រះរាជអាជ្ញា ។ លោក **Roux** បានបន្ថែមថា ឯកសារចងក្រងនេះមានភាពលំអៀង គួរគប្បីដាក់ជូនអង្គជំនុំជម្រះធ្វើសេចក្តីសម្រេចទទួលយកជាមុន ។ អង្គជំនុំជម្រះបានច្រានចោលការជំទាស់របស់មេធាវីការពារក្តី ដោយថ្លែងថា ខ្លួនទទួលយកឯកសារចងក្រងរបស់សហព្រះរាជអាជ្ញា ។ អង្គជំនុំជម្រះបានបញ្ជាក់បន្ថែមថា ភាគីទាំងអស់មានសិទ្ធិដាក់ជូនឯកសារចងក្រងដូចគ្នា តែដោយគ្មានការវិភាគបន្ថែមភ្ជាប់ជាមួយទេ ។

***តារប៉ះទង្គិចគ្នានៃប្រព័ន្ធច្បាប់: (ការជជែកដេញដោលពីប្រព័ន្ធច្បាប់ស៊ីវិល និងច្បាប់ Common Law)*** នាសប្តាហ៍នេះ មានការចោទសួរ២ផ្សេងទៀត ស្តីពីភាពខុសគ្នារវាង *ប្រព័ន្ធច្បាប់ Common Law និងច្បាប់ស៊ីវិល* នៅក្នុងនីតិវិធីជំនុំជម្រះ ។ បញ្ហាទី១ ពាក់ព័ន្ធនឹងបញ្ហា ថាតើសហមេធាវីការពារក្តីអាចពិភាក្សាជាមួយជនជាប់ចោទកំឡុងពេលផ្តល់សក្ខីភាពឬទេ ។ បញ្ហាទី២ ពាក់ព័ន្ធនឹងសំណួរនាំមុខ ឬសំណួរបិទ ។

**បញ្ហាទី១ :** មេធាវីដើមបណ្តឹងក្រុម២លោក **Alain Werner** បានចោទសួរអំពីសិទ្ធិរបស់មេធាវីការពារក្តីក្នុងការជជែកជាមួយកូនក្តីនៅក្រៅសវនាការ ស្តីពីការផ្តល់សក្ខីភាពដល់អង្គជំនុំជម្រះ ។ លោក **Alain** បានលើកឡើង នូវវិធាន៩០(២) នៃវិធានផ្ទៃក្នុង

ដែលបានចែងអំពីលំដាប់ដែលភាគីអាចចោទសួរជនជាប់ចោទ ។ បញ្ហានេះ គួរត្រូវបកស្រាយ ដើម្បីកំរិតសិទ្ធិមេធាវីការពារក្តីក្នុងការចោទសួរកូនក្តីរបស់ខ្លួន ស្តីពីភស្តុតាងដែលបានជូនអង្គជំនុំជម្រះ។ មេធាវីការពារក្តីលោក **Roux** បានលើកឡើងថា វាមិនដូចប្រព័ន្ធច្បាប់ **Common Law** ទេ ដែលជនជាប់ចោទត្រូវបានគេចោទសួរដូចសាក្សី ហើយក្នុងដំណើរការប្រព័ន្ធច្បាប់ស៊ីវិលបច្ចុប្បន្ននេះ ជនជាប់ចោទមិនធ្វើសម្បថទេនៅពេលសួរដេញដោល ។ លោក **Roux** មានប្រសាសន៍ថា *"គ្មាននរណាម្នាក់រារាំងគាត់មិនឱ្យនិយាយជាមួយកូនក្តីរបស់គាត់បានទេ កំឡុងពេលសវនាការ"* ។ គាត់បន្ថែមទៀតថា ការធ្វើដូច្នេះក្នុងប្រព័ន្ធច្បាប់ស៊ីវិលវាជា *"រឿងគ្រោះថ្នាក់"* ។ កាលពីថ្ងៃអង្គារ អង្គជំនុំជម្រះបានសម្រេចលើបញ្ហានេះ ដោយរក្សាជំហររបស់មេធាវីការពារក្តីក្នុងការឆ្លើយឆ្លងជាមួយជនជាប់ចោទ ។

**បញ្ហាទីពីរ :** កាលពីថ្ងៃអង្គារ មេធាវីការពារក្តី **Francois Roux** បានលើកការជំទាស់មួយទៅសហព្រះរាជអាជ្ញា ដែលប្រើសំណួរបិទ ឬសំណួរនាំមុខចំពោះកូនក្តីរបស់គាត់ ។ លោក **Roux** បានលើកហេតុផលថា សំណួរនាំមុខជាសំណួរដែលមានចម្លើយដែលចង់បាននៅក្នុងនោះ ហើយគាត់បន្ថែមថា ចំពោះភាគីដាក់បន្ទុកមិនត្រូវបានអនុញ្ញាតឱ្យសួរសំណួរនេះទេ ។ តាមការវែកញែករបស់សហព្រះរាជអាជ្ញា វាគួរឱ្យភ្ញាក់ផ្អើល ដែលលោក **Roux** បានគាំទ្រគោលការណ៍ប្រព័ន្ធច្បាប់ **Common Law** ចំពោះការហាមមិនឱ្យប្រើសំណួរនាំមុខ បើទោះជាពុំមានវិធានច្បាស់លាស់អនុវត្តលើករណីនេះ ។ អង្គជំនុំជម្រះបានច្រានចោលការជំទាស់របស់មេធាវីការពារក្តី ដោយមិនបានបញ្ជាក់ច្បាស់លាស់ថា សំណួរនាំមុខគួរត្រូវអនុញ្ញាតឱ្យសួរនៅក្នុងនីតិវិធី ឬសំណួររបស់សហព្រះរាជអាជ្ញាមិនចាត់ទុកថា ជាសំណួរនាំមុខ ឬសំណួរបិទ ។

***ភាពអានាគតិនៃឯកសារបកប្រែ :*** នៅថ្ងៃអង្គារ នៅពេលដែលសហព្រះរាជអាជ្ញាចោទសួរទៅជនជាប់ចោទ មេធាវីការពារក្តីបានលើកពីភាពអព្យាក្រិតនៃឯកសារបកប្រែដែលត្រូវយកមកប្រើប្រាស់ ។ តាមមេធាវីការពារក្តី ភាពមិនស៊ីសង្វាក់គ្នាបានកើតមានរវាងអត្ថបទបកប្រែ គឺចម្លើយសារភាពដែលមានចំណាររបស់ **ឌុច** និងកំហុសនៃការបកប្រែកំឡុងពេលសវនាការនៅពេលក្រឡាបញ្ជីអានឯកសារទាំងនោះ ។ សហព្រះរាជអាជ្ញាបានពន្យល់ថា ឯកសារបកប្រែទាំងនោះធ្វើដោយការិយាល័យសហព្រះរាជអាជ្ញា ដោយសារក្រុមបកប្រែរបស់តុលាការមានការងាររមមារញឹកច្រើន ។ ភាគីនីមួយៗរកសេវាបកប្រែជាចាំបាច់ បកប្រែទៅតាមដែលអាចធ្វើបាន ។ មេធាវីការពារក្តីបានស្នើថា សហព្រះរាជអាជ្ញាគួរតែកំណត់ចំណាំទៅលើឯកសារនីមួយៗដែលត្រូវបានបកប្រែ និងជូនព័ត៌មានដល់អង្គជំនុំជម្រះ និងភាគីឱ្យដឹងជាមុននូវបញ្ហាដែលថា *ការបកប្រែដោយឥតគិតថ្លៃ* ។ មេធាវីការពារក៏បានឱ្យដឹងផងដែរនូវកង្វល់របស់ខ្លួន ជាពិសេសពាក់ព័ន្ធនឹងឯកសារបកប្រែដោយមជ្ឈមណ្ឌលឯកសារច្បាប់កម្ពុជា (DC-Cam) អង្គជំនុំជម្រះលើកឡើងថា បញ្ហានេះជាវិធាន ដូច្នេះត្រូវលើកទៅធ្វើការសម្រេច នៅកាលបរិច្ឆេទក្រោយ ។

***ការតំណាងជនជាប់ចោទ :*** មេធាវីការពារក្តីលោក **François Roux** បានអវត្តមាននៅថ្ងៃពុធ និងថ្ងៃព្រហស្បតិ៍។ ទោះបីជាយ៉ាងណាក៏ដោយ វិធានផ្ទៃក្នុងមិនបានតម្រូវឱ្យមេធាវីការពារក្តីជាតិ និងអន្តរជាតិជំនួសលោក **Roux** ទេ។ អវត្តមានរបស់លោក **Roux** បានជះឥទ្ធិពលជាអវិជ្ជមាន ចំពោះអ្វីដែលមេធាវីការពារក្តីធ្វើការតស៊ូមតិសំរាប់សិទ្ធិរបស់ជនជាប់ចោទ ។ មេធាវីការពារក្តីជាតិលោក **ការ សាវុត្ថ** ហាក់ដូចជាមានសកម្មភាពតិចជាងមេធាវីការពារក្តីអន្តរជាតិក្នុងការការពារសិទ្ធិរបស់កូនក្តីខ្លួន។

គួរកត់សម្គាល់ថា មានបញ្ហាជាច្រើន ដែលជនជាប់ចោទខ្លួនឯងផ្ទាល់បានលើកឡើងការជំទាស់របស់ខ្លួនទៅនឹងការចោទសួរកំឡុងពេលនីតិវិធី ។ គាត់ថែមទាំងបានធ្វើការស្នើសុំទៅអង្គជំនុំជម្រះឱ្យមេធាវីដើមបណ្តឹងក្រុម២ បង្ហាញនូវឯកសារដែលលើកឡើងបន្ទាប់ពីការតវ៉ាពីរលើកដោយលើកថា គាត់មិនយល់នូវឯកសារបកប្រែទាំងនោះទេ ។

***សិទ្ធិនៅស្ងៀមមិនឆ្លើយ :*** កាលពីថ្ងៃពុធ ជាច្រើនលើកដែលជនជាប់ចោទបានព្យាយាមធ្វើការលើកឡើងនូវសិទ្ធិរបស់ខ្លួនក្នុងការនៅស្ងៀមមិនឆ្លើយ ។ គាត់បានផ្អែកលើពីរចំណុច គឺទីមួយ សំណួរមានភាពច្រំដែល និងទីពីរ តាមទស្សនៈរបស់គាត់សំណួរទាក់ទងនឹងអង្គហេតុផ្សេងគួរត្រូវពិភាក្សាលើកក្រោយនៃនីតិវិធី ។ ចំពោះចំណុចទាំងពីរនេះ អង្គជំនុំជម្រះបានអនុញ្ញាតជនជាប់ចោទ ។

## ៣. ការចូលរួមរបស់ជនរងគ្រោះ និង ការការពារ និងគាំទ្រសាក្សី និងជនរងគ្រោះ

***ដើម្បីបញ្ចៀសការមិនស្មើភាព សេចក្តីបង្គាប់មួយត្រូវបានសម្រេច :*** ប្រធានក្រុមប្រឹក្សាជំនុំជម្រះ លោកចៅក្រម **និល ណុន** បានកត់សម្គាល់ពី *"ការមិនស្មើភាព"* នៃលំដាប់សួរសំណួររបស់មេធាវីដើមបណ្តឹងនៅសប្តាហ៍នេះ ។ គាត់បានបង្ហាញពីបញ្ហាដែលថា មេធាវីដើមបណ្តឹងក្រុម៤តែងតែសួរសំណួរក្រោយគេព្រោះតែអង្គជំនុំជម្រះរក្សានូវការសួរសំណួរតាមលំដាប់លំដោយ ។ អង្គជំនុំជម្រះអនុញ្ញាតឱ្យមេធាវីដើមបណ្តឹងក្រុម៤ធ្វើការតាំងសំណួរមុនគេនៅអង្គហេតុបន្ទាប់ ។

***អត្តចរិករបស់ជនជាប់ចោទមិនសមរម្យដាក់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី :*** កាលពីថ្ងៃពុធ នៅការដំណាក់កាលចោទសួរជនជាប់ចោទបានបង្ហាញនូវការមិនគោរពមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេសមេធាវីអន្តរជាតិក្រុម២ **Silke Studzinsky** ។ ក្នុងពេលសួរដេញដោលជនជាប់ចោទហាក់ដូចជាអល់អែកដាក់កញ្ញា **Silke** ដោយការសើចចំអក និងការឆ្លើយឡកលើយ មុននឹងបដិសេធ និងលើកនូវសិទ្ធិនៅស្ងៀមមិនឆ្លើយ ។ បន្ទាប់មកអង្គជំនុំជម្រះបានធ្វើការស្តីបន្ទោសដល់ជនជាប់ចោទ ហើយស្នើឱ្យគាត់ *"ប្រើកាយវិការសមរម្យនៅពេលឆ្លើយសំណួរ ផ្តល់សិទ្ធិនៅស្ងៀមមិនឆ្លើយ និងមិនត្រូវសើចចំអកនៅពេលឆ្លើយ"* ។

***ស្នើសុំបញ្ជាក់អត្តសញ្ញាណមេធាវីដើមបណ្តឹងនៅក្នុងលិខិត :*** ការស្នើសុំមិនមែនជាលើកទី១ ដែលត្រូវលើកឡើងពាក់ព័ន្ធនឹងអត្តចារិករបស់ជនជាប់ចោទ ។ ការតវ៉ាត្រូវបានលើកឡើងដោយមេធាវីដើមបណ្តឹងក្រុម២ តាមរយៈលិខិតស្នើសុំអំពីកាយវិការរបស់ជនជាប់ចោទមិនគោរពមេធាវី ។ បញ្ហានេះ បានជំរុញឱ្យដើមបណ្តឹងក្រុម១ ដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរទៅអង្គជំនុំជម្រះដើម្បីធានាថា រាល់សំណើទាំងអស់ដែលដាក់ជូនដោយដើមបណ្តឹងមានដាក់ឈ្មោះក្រុម ។ សំណើនេះទំនងជាចង់បង្ហាញថា មិនចង់ឱ្យសំណើនោះតំណាងឱ្យដើមបណ្តឹងទាំងអស់នោះទេ ។ កាលពីថ្ងៃចន្ទ័ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ កញ្ញា **Silke** បានឆ្លើយតបចំពោះបញ្ហានោះថា ដំបូងគាត់បានធ្វើជាលាយលក្ខណ៍អក្សរ តែបន្ទាប់គាត់ធ្វើដោយផ្ទាល់មាត់នៅមុខអង្គជំនុំជម្រះ ។ គាត់បន្ថែមថា ហត្ថលេខាក៏អាចបញ្ជាក់ថាដើមបណ្តឹងក្រុមណាជាអ្នកដាក់សំណើ ព្រោះពេលខ្លះសមាជិកក្នុងក្រុម១មិនមានជំហរដូចគ្នាទេ ហើយពេលខ្លះគាំទ្រជំហររបស់ក្រុមផ្សេងក៏មាន ។ ការលើកឡើងនេះបង្ហាញយ៉ាងច្បាស់ថា ទី១ ក្រុមមេធាវីដើមបណ្តឹងមួយចំនួនមិនចង់ពាក់ពន្ធ័ជាមួយសំណើដែលធ្វើឡើងដោយក្រុមផ្សេងទេ ។ ទី២ មេធាវីនៅក្រុមជាមួយគ្នាពេលខ្លះក៏មិន

យល់ស្របដែរ ។ អង្គជំនុំជម្រះសម្រេចបញ្ហានេះ នៅរសៀលថ្ងៃអង្គារ ដោយបដិសេធលើសំណើរបស់មេធាវីដើមបណ្តឹងក្រុម២ និងបង្គាប់ឱ្យភាគីថែងឱ្យបានច្បាស់តើនរណាជាអ្នកដាក់សំណើនេះ ។

## ៤. ការគ្រប់គ្រងការជំនុំជម្រះ

***ការគ្រប់គ្រងផ្នែកសវនាការ :*** អង្គជំនុំជម្រះនៅតែបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំ ដើម្បីចៀសវាងការពន្យាពេលនីតិវិធី នៅសប្តាហ៍នេះ ។ ជាពិសេស លោកស្រីចៅក្រម **Sylvia Cartwright** បានព្យាយាមពន្យល់យ៉ាងប្រញាប់ ពីការស្នើសុំពន្យាពេលដាក់ជូនឯកសារដោយមេធាវី សូមឱ្យធ្វើដោយផ្ទាល់មាត់ជំនួសវិញ ។ នេះគ្រាន់តែជាបញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើនដែលអង្គជំនុំជម្រះការពារការបញ្ចូលឯកសារព្រោះនាំឱ្យពន្យាពេលនីតិវិធី ។ ទោះបីជាខិតខំយ៉ាងណាក៏ដោយ នីតិវិធីនៅតែដំណើរការយឺតនៅសប្តាហ៍នេះ ហើយចៅក្រមនៅតែបន្តរក្សាកាលវិភាគសម្រាកដូចសប្តាហ៍មុន និងតែងតែពន្យាពេលនីតិវិធី ។

កាលពីថ្ងៃអង្គារ និងថ្ងៃពុធ ប្រធានអង្គជំនុំជម្រះក្រើនរំលឹកជាញឹកញាប់ដល់ភាគី កុំឱ្យសួរចាកពីប្រធានបទការបង្កើតមន្ទីរ ស-២១ ។ គួរកត់សម្គាល់ថា ទោះបីជាការក្រើនរំលឹកជាញឹកញាប់ មេធាវីមួយចំនួននៅតែសួរសំណួរប្រាស់ចាកពីអង្គហេតុដែលបានកំណត់។ អង្គជំនុំជម្រះបានឱ្យដឹងថា សកម្មភាពតវ៉ាមានច្រើននៅថ្ងៃពុធ ព្រមទាំងប្រកាសថា នឹងអនុវត្តសិទ្ធិដើម្បីបង្អាក់សំណួរដែលអង្គជំនុំជម្រះគិតថាមិនពាក់ព័ន្ធ ។ ភាគីហាក់ដូចជាក៏រិតសំណួររបស់ខ្លួន ជាលទ្ធផលសំណួរច្រំដែល ដូចជាមានតិចនៅសប្តាហ៍នេះ។

***កាលវិភាគនៃដំណើរការសវនាការ :*** ដោយយោងតាមសំណូមពររបស់មេធាវីដើមបណ្តឹងលោក **Alain Werner** អង្គជំនុំជម្រះបានធ្វើការធានាដល់ភាគីថា កាលវិភាគថ្មីនៃដំណើរការសវនាការនឹងត្រូវចេញនៅថ្ងៃព្រហស្បតិ៍នេះ រហូតដល់ខែឧសភា និងមិថុនា ។ គាត់បានចង្អុលបន្ថែមថា ព័ត៌មាននៃកាលវិភាគសំម្រាប់សវនាការនឹងត្រូវផ្តល់ឱ្យយ៉ាងតិច ពីរទៅបីសប្តាហ៍មុន ។ ក្រោយមកអង្គជំនុំជម្រះបានប្រកាសដល់ភាគីថា នៅថ្ងៃទី ០១ ដល់ ០៥ ខែមិថុនា ឆ្នាំ២០០៩ នឹងមិនមានសវនាការកើតឡើងទេ ព្រោះតែអង្គបុរេនឹងធ្វើការជំនុំជម្រះនៅពេលនោះ ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះមិនបានដឹងមុននូវការសម្រាកក្នុងខែកក្កដា និងខែសីហាទេ។ អង្គជំនុំជម្រះនឹងធ្វើការពិភាក្សាជាមុនជាមួយអង្គបុរេ ថាតើអង្គបុរេនឹងធ្វើការជំនុំជម្រះនៅចុងខែខែកក្កដាឬទេ។

តាមសំណូមពររបស់មេធាវីដើមបណ្តឹងលោក **Philippe Cannone** អង្គជំនុំជម្រះបានធានាថា ការសម្រេចសេចក្តីពាក់ព័ន្ធនឹងការទទួលឯកសាររបស់មជ្ឈមណ្ឌលឯកសារច្បាប់កម្ពុជា និងការបកប្រែនឹងពិចារណា បន្ទាប់ពីការសម្រាកពីរសប្តាហ៍ ព្រោះថាបញ្ហានេះត្រូវការពេលវេលាសមរម្យក្នុងការពិភាក្សាលម្អិត ។

***វិន័យក្នុងសាលសវនាការ :*** ដូចដែលបានលើកឡើង ភាពតានតឹងរវាងជនជាបចោទ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី **Silke Studzinsky** បានកើតឡើងនៅក្នុងសប្តាហ៍នេះ ។ ជនជាប់ចោទហាក់ដូចជានិយាយវែងឆ្ងាយនៅពេលឆ្លើយនឹងសំណួររបស់មេធាវី **Silke Studzinsky** ហើយមេធាវី **Silke Studzinsky** បានកាត់សំដីរបស់គាត់ ខណៈដែលគាត់មិនបានឆ្លើយចំនឹងសំណួររបស់ខ្លួន ។ **ឌុច** បានបដិសេធមិនឆ្លើយនឹងសំណួរមួយចំនួនដែលមេធាវីបានចោទសួរ ហើយបានធ្វើការឆ្លើយតបបែបផ្ចើន

ចំពោះសំណួរដែលគាត់ចង់ឆ្លើយ ។ ឥរិយាបថរបស់គាត់បានបង្ហាញយ៉ាងច្បាស់នូវការមិនគោរព និងព្រងើយកន្តើយចំពោះសំណួររបស់មេធាវី បើទោះជាសំណួរមានលក្ខណៈងាយស្រួល ឬពិបាកយល់ក៏ដោយ ។ នៅពេលខ្លះ គាត់បានសើចចំអកដាក់មេធាវី ។ ក្រោយមក អង្គជំនុំជម្រះបានស្តីបន្ទោសជនជាប់ចោទអំពីសកម្មភាពដែលបានសំដែងចេញ ។ (សូមអានផ្នែកដើមបណ្តឹងរដ្ឋប្បវេណីនៅចំណុចខាងលើ)

***កង្វល់ពាក់ព័ន្ធនឹងបញ្ហាបកប្រែ :*** បញ្ហានៃការបកប្រែនៅតែបន្តកើតមានក្នុងកំឡុងពេលកិច្ចដំណើរការនីតិវិធី បើទោះបីជាបញ្ហានេះមិនបានកើតឡើងច្រើនដូចកាលពីសប្តាហ៍មុនក៏ដោយ ។ នេះប្រហែលជា ដោយសារតែមិនមានការផ្តល់សក្ខីភាពរបស់សាក្សីនៅសប្តាហ៍នេះ ។ ម៉្យាងទៀត ជនជាប់ចោទដែលស្តាប់យល់ភាសាបារាំង ហាក់ដូចជាមានការប្រិតប្រៀងដើម្បីធានាថា សក្ខីភាពរបស់ខ្លួនត្រូវបានបកប្រែដោយត្រឹមត្រូវ ។ លោកស្រីចៅក្រម **Sylvia Cartwright** បានប្រាប់ទៅដល់ភាគីឱ្យកែតម្រូវកំហុសនៃការបកប្រែភ្លាមៗប្រសិនបើមាន ។

***វត្តមានអ្នកចូលរួមនៅសាលសវនាការសាធារណៈ :*** នាសប្តាហ៍នេះ អ្នកចូលរួមនៅក្នុងសាលសវនាការសាធារណៈមានចំនួនច្រើនដែលចំនួនជាមធ្យមពី ១៥០ ទៅ ២០០នាក់ នៃថ្ងៃនីមួយៗ។ ក្រុមអ្នកឃ្លាំមើលដំណើរការសវនាការ បានកត់សម្គាល់ថា មានការចូលរួមពី ប្រជាជន សិស្ស-និស្សិត និងបណ្តាអង្គការនានា...។ នៅថ្ងៃច័ន្ទ ប្រជាជនប្រមាណជា ៧០នាក់ មកពី ឃុំព្រៃវែង ខណ្ឌដង្កោ រាជធានីភ្នំពេញ ត្រូវបានរៀបចំឱ្យចូលរួម ។ នៅថ្ងៃពុធ ដោយមានការជួយឧបត្ថម្ភពីមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) និងពីផ្នែកកិច្ចការសាធារណៈរបស់តុលាការ ប្រជាជនប្រមាណជា ១០០នាក់ មកពីស្រុកកោះធំ ខេត្តកណ្តាល និងប្រមាណជា ៧០នាក់ មកពីខណ្ឌដង្កោ រាជធានីភ្នំពេញ ចូលរួមសវនាការពេញមួយថ្ងៃ ។ សិស្ស-និស្សិត សាកលវិទ្យាល័យមួយចំនួនក៏បានចូលរួមកុះករនៅថ្ងៃច័ន្ទ និងអង្គារ ។ បុគ្គលិករបស់អង្គការ UNDP ប្រមាណជា ៦០នាក់ បានចូលរួមនាព្រឹកថ្ងៃ ព្រហស្បតិ៍ដែរ ។

***ការចូលរួមរបស់ភាគី :*** ដើមបណ្តឹងរដ្ឋប្បវេណីនៅតែមានវត្តមានចំនួន ៣នាក់ ដដែល នៅក្នុងបន្ទប់សវនាការ នាសប្តាហ៍នេះ។ ទោះជាយ៉ាងណាក៏ដោយ មេធាវីរបស់ពួកគេមានវត្តមាននៅគ្រប់កិច្ចនីតិវិធី ។ សហព្រះរាជអាជ្ញា ទាំងជាតិ និងអន្តរជាតិ (លោកស្រី **ជា លាង** និង លោក **Rober Petit**) មិនមានវត្តមានទេនៅកិច្ចដំណើរការនីតិវិធីនាសប្តាហ៍នេះ ។ លោក **តាន់ សេណារ៉ុង** មានវត្តមានមុខអង្គជំនុំជម្រះក្នុងនាមសហព្រះរាជអាជ្ញាជាតិ និងលោក **Alex Bates** ក្នុងនាមសហព្រះរាជអាជ្ញាអន្តរជាតិ។ ដូចបានកត់សម្គាល់ខាងលើ មេធាវីការពារក្តីលោក **François Roux** អវត្តមាននៅថ្ងៃពុធ និងព្រហស្បតិ៍ ។ គាត់បានប្រកាសពីអវត្តមានរបស់ខ្លួនកាលពីថ្ងៃអង្គារ និងបានសំដែងឱ្យដឹងថា ដោយសារតែមានការតំរូវភ្លាមៗនូវវត្តមានរបស់ខ្លួននៅឯតុលាការពិសេស **លីបាណាន់** នៅទីក្រុងឡាអេ ។ ការជូនដំណឹងរបស់គាត់ ដើម្បីបង្ការឱ្យមេធាវីជំនួយរបស់គាត់ចូលជំនួសនៅកិច្ចដំណើរការនីតិវិធី បើទោះបីជាទីប្រឹក្សាច្បាប់អន្តរជាតិកញ្ញា **Héleyn Uñac** មានវត្តមានក៏ដោយ ។ មេធាវីការពារក្តីជាតិលោក **ការ សាវុត្ថ** មានវត្តមាននៅសប្តាហ៍នេះ។

## តារាងគ្រប់គ្រងពេលវេលា

គួរកត់សម្គាល់ថា អង្គជំនុំជម្រះបានពន្យាពេល ២០នាទី នាពេលចាប់ផ្តើមនៅព្រឹកថ្ងៃពុធនេះ ដើម្បីពិភាក្សានូវបញ្ហាសំខាន់ៗមួយចំនួន។

| ថ្ងៃ- កាលបរិច្ឆេទ | ចាប់ផ្តើម | សំរាក- ព្រឹក | អាហារថ្ងៃត្រង់ | សំរាក- រសៀល | បញ្ឈប់ | សរុបចំនួនម៉ោង |
|---|---|---|---|---|---|---|
| ច័ន្ទ ២៧.០៤.០៩ | ០៩:០៥ | ១០:៣០ –១១:១០ | ១២:០៥ – ១៣:៤០ | ១៥:០០- ១៥:២៥ | ១៦:២៥ | ៤ម៉ោ ៤០នាទី |
| អង្គារ ២៨.០៤.០៩ | ០៩:១០ | ១០:២៥-១១:០០ | ១២:០៥-១៣:៣៥ | ១៤:៤០-១៥:២០ | ១៦:៣០ | ៤ម៉ោ ៣៥នាទី |
| ពុធ ២៩.០៤.០៩ | ០៩:១៥ | ១០:៤៥ – ១១:៤៥ | ១២:០៥ – ១៣:៣៥ | ១៤:៥០– ១៥:០៥ | ១៦:១០ | ៤ម៉ោ ២៥នាទី |
| ព្រហស្បតិ៍ ៣០.០៤.០៩ | ០៩:១៥ | ១០:៤០ –១១:០៨ | ១២:០០- ១៣:៥៨ | ១៥:០៥- ១៥:២៨ | ១៦:២០ | ៤ម៉ោ ១៦នាទី |
| **ចំនួនម៉ោងជាមធ្យម :** **៤ម៉ោ ២៩នាទី**<br>**ចំនួនម៉ោងសរុបសំរាប់សប្តាហ៍នេះ :** **១៧ម៉ោ ៥៦នាទី**<br>**ចំនួន ម៉ោង ថ្ងៃ និង សប្តាហ៍ សរុបសំរាប់សវនាការបីសប្តាហ៍ :** **៦៥ម៉ោ** **ថ្ងៃសវនាការ ១៥ថ្ងៃ** **សប្តាហ៍ទី៤** | | | | | | |

---

**អំពីកម្មវិធីអ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម** ( "កម្មវិធី" ) **:** ជាកម្មវិធីរបស់អង្គការ the Asian International Justice Initiative (AIJI) ដែលជាកិច្ចសហការរវាង U.C. Berkeley War Crimes Studies Center និង East-West Center ។ កម្មវិធីនេះចេញរបាយការណ៍ប្រចាំសប្តាហ៍ អំពីកិច្ចដំណើរការនីតិវិធីសវនាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ឬ តុលាការកាត់ទោសខ្មែរក្រហម ។ បច្ចុប្បន្ន កម្មវិធីនេះកំពុងតែឃ្លាំមើលដំណើរការនៃការកាត់ទោសលើសំណុំរឿង កាំង ហ្គិចអ៊ាវ ហៅ ឌុច ដែលជារឿងក្តីដំបូងឈានដល់ដំណាក់កាលអង្គជំនុំជម្រះ។

របាយការណ៍ប្រចាំសប្តាហ៍នេះ ត្រូវបានសរសេរដោយក្រុមអ្នកឃ្លាំមើលតុលាការដែលដឹកនាំដោយលោកស្រី **Michelle Staggs** នាយិការង នៃអង្គការ AIJI ដែលមានសមាសភាពដូចខាងក្រោម:

**ក្រុមទី១.**
- លោកស្រី **ជូ វិនាថ :** ប្រធានកម្មវិធីសង្កេតការណ៍តុលាការនៃ CSD
- លោក **ភ័ក្រ្ត សាវ៉ន :** បុគ្គលិកអង្គការ UNOHCHR
- កញ្ញា **Yvette Anthony** : សិង្ហបុរី
- កញ្ញា **Sybylle Dischler** : ស្វីស
- លោក **Florian Hansen** : អាល្លឺម៉ង់

**ក្រុមទី២.**
- កញ្ញា. **សេក សុវណ្ណា :** មេធាវី អង្គការ CLEC
- លោក **ង៉ែត សុវណ្ណនិត :** បុគ្គលិកអង្គការ KID
- កញ្ញា **Aviva Nababan** : ឥណ្ឌូនេស៊ី
- កញ្ញា **Romana Weber** : ស្វីស
- កញ្ញា **Binxin Zhang** : ចិន

កម្មវិធីនេះ បានសហការជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) ដើម្បីផ្សព្វផ្សាយរបាយការណ៍នេះ ។ លោក- អ្នកអាចរកបាននូវរបាយការណ៍នេះជាភាសាខ្មែរ និង អង់គ្លេស នៅក្នុង www.csdcambodia.org; www.kidcambodia.org និង http://socrates.berkeley.edu/~warcrime/ ។